# ចុះឈ្មោះដើម្បីបោះឆ្នោត សំរាប់ការបោះឆ្នោតសាលាសង្កាត់នៅខែវិច្ឆិកានេះ

# គ្រប់ទាំងសាលាសង្កាត់ក្នុងរដ្ឋវិចតូរីយ៉ានឹងរៀបចំបោះឆ្នោតនៅក្នុងខែវិច្ឆិកា។

”ប្រសិនបើលោកអ្នកជាពលរដ្ឋអូស្ត្រាលីមានអាយុ១៨ឆ្នាំ ឬច្រើនជាងនេះ លោកអ្នកត្រូវចុះឈ្មោះ ហើយបោះឆ្នោតនៅក្នុងសាលាសង្កាត់ប្រចាំតំបន់របស់លោកអ្នក” លោក Steve Tully ស្នងការចាត់ចែងការបោះឆ្នោតមានប្រសាសន៏។

គ្រប់ពលរដ្ឋវិចតូរីយ៉ាដែលមានសិទ្ធិទាំងអស់ត្រូវចុះឈ្មោះ ហើយរៀបចំព័ត៏មានចុះឈ្មោះបោះឆ្នោតរបស់ខ្លួនឲ្យបានទាន់ពេលថ្មីបំផុត សំរាប់ការបោះឆ្នោតសាលាសង្កាត់ឲ្យបានទាន់**ម៉ោង៨រសៀល នៅថ្ងៃសុក្រ ទី៣ ខែតុលា**។

ប្រសិនបើលោកអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតប្រចាំរដ្ឋ នោះលោកអ្នកនឹងមានឈ្មោះចុះជាស្វ័យប្រវត្តិសំរាប់ការបោះឆ្នោតសាលាសង្កាត់។

ក៏ប៉ុន្តែ ប្រសិនបើលោកអ្នកបានផ្លាស់ប្តូរទីលំនៅក្នុងពេលថ្មីៗនេះ ឬទើបតែបានចូលអាយុ១៨ឆ្នាំ នោះលោកអ្នកត្រូវការយកហ្វ៊មបំពេញចុះឈ្មោះបោះឆ្នោតឲ្យបានទាន់ថ្ងៃទី៣ ខែតុលាដែលត្រូវជាថ្ងៃកំណត់។

ហ្វ៊មចុះឈ្មោះបោះឆ្នោតមាននៅតាមការិយាល័យប្រៃសណីយ៏ Centrelink ការិយាល័យគណៈកម្មការចាត់ចែងការបោះឆ្នោតអូស្ត្រាលី ផ្សារធំ Coles supermarket ឬអាចទាញយកបានពីវ៉ិបសាយ www.vec.vic.gov.au ឬអាចស្នើសុំឲ្យគេផ្ញើទៅលោកអ្នក។ សូមទូរស័ព្ទលេខ 13 18 32 ឬ 9209 0192 ដើម្បីសុំជំនួយអ្នកបកប្រែភាសា។

ក៏មានជំពូកចុះឈ្មោះពិសេសផងដែរសំរាប់អ្នករស់នៅតាមទីលំនៅដ្ឋានដែលបង់ពន្ធដីធ្លីសាលាក្រុង អ្នកជ្រើសតាំងរបស់ក្រុមហ៊ុន និងជនដែលមិនមែនជាពលរដ្ឋអូស្ត្រាលី ដែលបង់ពន្ធដីធ្លីសាលាក្រុង ហើយមានបំណងចង់បោះឆ្នោត។

ដើម្បីទទួលយកព័ត៏មានច្រើនថែមទៀត សូមបើកមើលវ៉ិបសាយ www.vec.vic.gov.au ឬទូរស័ព្ទលេខ 13 18 32 ឬ 9209 0192 ដើម្បីសុំជំនួយអ្នកបកប្រែ ភាសា។